វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- គោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជាអាចសម្រេចបាន ប៉ុន្តែត្រូវមានការបង្កើនល្បឿនការវិនិយោគបន្ថែម
- ប្រទេសសឹង្ហបុរីនាំមុខគេនៃចំណាត់ថ្នាក់មូលធនដែនសមុទ្រ (Maritime capital) ក្នុងរយៈពេលបួនឆ្នាំជាប់ៗគ្នា
- សេដ្ឋកិច្ចអាមេរិចបានបន្ថែមការងារចំនួន ១៩៦ ០០០ តែមិនធ្វើអោយអត្រានិកម្មភាពប្រែប្រួលទេ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះ-បណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### គោលដៅអភិវឌ្ឍប្រកបដោយចិរភាព អាចសម្រេចទៅបាន ប៉ុន្តែត្រូវបង្កើនល្បឿនការវិនិយោគបន្ថែម

នៅក្នុងអត្ថបទអត្ថាធិប្បាយមួយដែលបានផ្សព្វផ្សាយនាសប្តាហ៍នេះ លេខាធិការប្រតិបត្តិនៃគណៈកម្មការទោះបីជាកម្ពុជាមានកំណើនសេដ្ឋកិច្ចល្អ និងការផ្លាស់ប្តូរទាំងផ្នែកសេដ្ឋកិច្ច និងសង្គមអំឡុងពេលថ្មីៗនេះក៏ដោយ ក៏ត្រូវតែមានការបង្កើនល្បឿននៃការអភិវឌ្ឍនេះ ដើម្បីអាចសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចិរភាពត្រឹមឆ្នាំ២០៣០។

អង្គការដដែលបានធ្វើការប៉ាន់ស្មានថា មានតម្រូវការវិនិយោគបន្ថែមប្រមាណ១,៥ទ្រីលានដុល្លារ សម្រាប់អាស៊ី និងតំបន់ប៉ាស៊ីហ្វិក ខណៈដែលប្រទេសកម្ពុជា ត្រូវការការវិនិយោគបន្ថែមប្រមាណ ៣ ដុល្លារក្នុងមនុស្សម្នាក់ៗក្នុងមួយថ្ងៃ (៥,៤%នៃផសសប្រចាំឆ្នាំ) ដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចិរភាព។ លេខាធិការប្រតិបត្តិនៃគណៈកម្មការ ស្ថិតនៅក្រោមសមត្ថភាពសារពើពន្ធរបស់តំបន់នេះដែលអាចសម្រេចបាន និងបានផ្តល់អនុសាសន៍ឱ្យផ្តោតលើការរៀបចំធ្វើថវិកាដែលឆ្លើយតបនឹងយេនឌ័រឲ្យមានលក្ខណៈស៊ីជម្រៅ ដែលវាជាមធ្យោបាយក្នុងការជំរុញលទ្ធផលនៃការអភិវឌ្ឍអោយកាន់តែមានភាពល្អប្រសើរបន្ថែមទៀត។

ការថ្លែងរបស់លេខាធិការប្រតិបត្តិ ធ្វើឡើងបន្ទាប់ពីកម្មវិធីដែលរៀបចំធ្វើឡើងដោយ ESCAP នៅទីក្រុងបាងកក ដែលជាផ្នែកមួយនៃកម្មវិធីទី៦នៅក្នុងវេទិកាអាស៊ី-ប៉ាស៊ីហ្វិកទៅលើការអភិវឌ្ឍប្រកបដោយចិរភាព។ កម្មវិធីនេះ បានអញ្ជើញនូវសមាជិករដ្ឋាភិបាលរបស់ប្រទេសក្នុងតំបន់អាស៊ីខាងត្បូង ក្រុមអ្នកបច្ចេកទេសគំនិត និងអង្គការសង្គមស៊ីវិល ដើម្បីជួប និងចែករម្លែកនូវគំនិតអភិវឌ្ឍប្រកបដោយចិរភាព(សេចក្តីប្រកាសព័ត៌មាន)។

**តារាងប្រចាំសប្តាហ៍៖** កំណើនផសស សម្រាប់មនុស្សម្នាក់ៗ

កំណើនផសស សម្រាប់មនុស្សម្នាក់ៗប្រចាំឆ្នាំនៅក្នុងប្រទេសកម្ពុជាមានការប្រែប្រួលចន្លោះពី៤% ទៅ៦% តាំងពីឆ្នាំ២០១៦ ហើយត្រូវបានព្យាករណ៍ថានឹងមានកំណើនតិចតួចក្នុងឆ្នាំ២០១៩ ចំនួន

៤,២% និងឆ្នាំ២០២០ ចំនួន ៤,៥% នេះបើយោងទៅតាមទស្សនវិស័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០១៩។

**អត្រាកំណើនផសស សម្រាប់មនុស្សម្នាក់ៗរបស់កម្ពុជា (គិតជាភាគរយប្រចាំឆ្នាំ)**




ប្រភព៖ [ធនាគារអភិវឌ្ឍន៍អាស៊ាន]

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ប្រទេសសិង្ហបុរីនាំមុខគេនៃចំណាត់ថ្នាក់មូលធនដែនសមុទ្រ (Maritime capital) ក្នុងរយៈពេលបួនឆ្នាំជាប់ៗគ្នា

យោងទៅតាម[របាយការណ៍មូលធនដែនសមុទ្រ]ឈានមុខចេញដោយ Menon Economics ប្រទេសសិង្ហបុរី ជាប់ចំណាត់ថ្នាក់នាំមុខគេនៃមូលធនដែនសមុទ្រ ក្នុងរយៈបួនឆ្នាំជាប់ៗគ្នា ។

របាយការណ៍បានប្រៀបធៀបទីក្រុងដោយឈរលើមូលដ្ឋាន ៥សូចនាករ ១). មជ្ឈមណ្ឌលដឹកជញ្ជូន ២). ច្បាប់ និងហិរញ្ញវត្ថុដែនសមុទ្រ ៣). បច្ចេកវិទ្យាដែនសមុទ្រ កំពង់ផែ និងឡូជីស្ទីក ៤). ភាពទាក់ទាញ និង៥). ភាពប្រកួតប្រជែង។ របាយការណ៍នេះ ផ្តល់នូវការស្វែងយល់ស៊ីជម្រៅអំពីអាជីវកម្មដែនសមុទ្រទៅលើអ្វីដែលទីក្រុងកំពង់ផែបានផ្តល់អោយល្អបំផុត ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធទន់ និងរឹង និងភាពប៉ិនប្រសប់។

ទីក្រុង Hamburg ជាប់ចំណាត់ថ្នាក់ទីពីរ បន្ទាប់មកគឺ Rotterdam, Hong Kong, London និង Shanghai អ្នកជំនាញព្យាករណ៍ថា ប្រទេសសិង្ហបុរីនឹងរក្សាបានចំណាត់ថ្នាក់កំពូលក្នុងកំឡុងប្រាំឆ្នាំទៅមុខទៀត ទោះបីជាប្រទេសនេះនឹងប្រឈមការប្រកួតប្រជែងខ្លាំងពីសៀងហៃ និងឌូបៃ ក៏ដោយ។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### សេដ្ឋកិច្ចអាមេរិចបានបន្ថែមការងារចំនួន ១៩៦ ០០០ តែមិនធ្វើអោយអត្រានិកម្មភាពប្រែប្រួលទេ

យោងទៅតាមការិយាល័យស្ថិតិការងារសហរដ្ឋអាមេរិក បានបង្ហាញថា សេដ្ឋកិច្ចសហរដ្ឋអាមេរិកបានបន្ថែមការងារចំនួន ១៩៦ ០០០ នៅក្នុងខែមីនា ដែលធ្វើឲ្យអត្រានិកម្មភាពមិនប្រែប្រួល នៅអត្រា ៣,៨% ដូចកាលពីខែមុនដដែល។

ការងារដែលបន្ថែមនោះគឺនៅក្នុងវិស័យថែទាំសុខភាព ជំនាញវិជ្ជាជីវៈ និងសេវាកម្មបច្ចេកទេស។ កំណើនការងារសរុប ដែលមិនរាប់បញ្ចូលវិស័យកសិកម្ម គឺខ្ពស់ជាងកំណើនជាមធ្យមប្រចាំខែចំនួន ១៨០ ០០០ ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ ប៉ុន្តែទាបជាងកំណើនជាមធ្យមប្រចាំខែក្នុងត្រីមាសទី១ឆ្នាំ២០១៨ ដែលមានចំនួន ២២៣ ០០០។

ម្យ៉ាងវិញទៀត ចំនួនអ្នកគ្មានការងារធ្វើនៅតែមិនប្រែប្រួល ដោយមានចំនួន ៦,២លាន ធៀបនឹងខែមុន។ ដូចគ្នានេះដែរ ចំនួនអ្នកគ្មានការងារធ្វើរយៈពេលវែងក៏មិនមានការប្រែប្រួលដែរ គឺមានចំនួន ១,៣លានដដែល។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

សប្តាហ៍ក្រោយ ជាសប្តាហ៍ដែលមានយឺតយ៉ាវក្នុងការចេញផ្សាយទិន្នន័យ ដោយសារប្រទេសភាគច្រើនក្នុងតំបន់ ចូលរួមក្នុងការសាទរពិធីចូលឆ្នាំថ្មី។ ទោះបីជាយ៉ាងណាក៏ដោយ យើងនឹងទទួលបានទិន្នន័យទៅលើកំណើនផសសរបស់ប្រទេសចិនសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩ តុល្យភាពពាណិជ្ជកម្មនៅក្នុងតំបន់អឺរ៉ូ និងប្រទេសឥណ្ឌូនេស៊ីនឹងរៀបចំការបោះឆ្នោតនៅថ្ងៃពុធ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី១៥ ខែមេសា ឆ្នាំ២០១៩

- តុល្យភាពពាណិជ្ជកម្ម របស់ឥណ្ឌូនេស៊ី សម្រាប់ខែមីនា
- ទិន្នន័យការដាក់ដេញថ្លៃបណ្ណរតនាគាររបស់អាមេរិក ដែលមានរយៈពេល៣ខែ និង៦ខែ

ថ្ងៃអង្គារ ទី១៦ ខែមេសា ឆ្នាំ២០១៩

- ទិន្នន័យការលក់ឡានរបស់ ឥណ្ឌូនេស៊ីសម្រាប់ខែមីនា
- ទិន្នន័យផលិតកម្មឧស្សាហកម្មរបស់អាមេរិក  សម្រាប់ខែមីនា
- តុល្យភាពពាណិជ្ជកម្មរបស់ជប៉ុន សម្រាប់ខែមីនា

ថ្ងៃពុធ ទី១៧ ខែមេសា ឆ្នាំ២០១៩

- តុល្យភាពពាណិជ្ជកម្មរបស់សឹង្ហបុរី សម្រាប់ខែមីនា
- កំណើនផសសរបស់ចិន សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩
- ទិន្នន័យផលិតកម្មឧស្សាហកម្មរបស់ចិន សម្រាប់ខែមីនា
- ទិន្នន័យផលិតកម្មឧស្សាហកម្មរបស់ជប៉ុន សម្រាប់ខែមីនា
- តុល្យភាពពាណិជ្ជកម្មរបស់សហគមន៍អឺរ៉ុប សម្រាប់ខែកុម្ភៈ
- អត្រាអតិផរណារបស់សហគមន៍អឺរ៉ុប សម្រាប់ខែមីនា
- ការបោះឆ្នោតរបស់ឥណ្ឌូនេស៊ី

ថ្ងៃព្រហស្បតិ៍ ទី១៨ ខែមេសា ឆ្នាំ២០១៩

- ការសម្រេចអត្រាការប្រាក់របស់កូរ៉េខាងត្បូង
- អត្រានិកម្មភាពរបស់ទីក្រុងហុងកុង សម្រាប់ខែមីនា
- ទិន្នន័យនៃការអះអាងនិកម្មភាព របស់អាមេរិក ថ្ងៃ១៣/មេសា
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិតនៅកូរ៉េខាងត្បូង សម្រាប់ខែមីនា
- អត្រាអតិផរណារបស់ជប៉ុន សម្រាប់ខែមីនា

ថ្ងៃសុក្រ ទី១៩ ខែមេសា ឆ្នាំ២០១៩

- ទិន្នន័យការអនុញ្ញាតសាងសង់ផ្ទះ និងអគាររបស់អាមេរិក សម្រាប់ខែមីនា